# ផែនទីបង្ហាញផ្លូវដើម្បីសម្រេចបាននូវសង្គមដែលជនបរទេសអាចរួមរស់ជាមួយគ្នាបាន(កែសម្រួលដោយផ្នែក សម្រាប់ឆ្នាំ2023)
# (សេចក្តីពន្យល់ត្រួសៗ)

នៅខែមិថុនា ឆ្នាំ2022 យើងបានអនុម័តផែនទីបង្ហាញផ្លូវដែលបង្ហាញពីចក្ខុវិស័យនៃសង្គមរួមរស់ជាមួយជនបរទេសដែលគួរតែជាទិសដៅនៃប្រទេសជប៉ុន និងបង្ហាញពីបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងរយៈពេលមធ្យមនិងវែង ព្រមទាំងវិធានការជាក់លាក់ ដើម្បីសម្រេចបាន។ នាពេលថ្មីៗនេះ ដើម្បីធានាបាននូវការអនុវត្តជាក់លាក់នៃវិធានការ យើងបានធ្វើការត្រួតពិនិត្យបន្ទាប់ពីបានស្តាប់យោបល់របស់អ្នកជំនាញស្តីពីស្ថានភាពនៃការអនុវត្តនោះ ព្រមទាំងបានពិនិត្យមើលឡើងវិញនូវវិធានការ។

## 1 ចក្ខុវិស័យនៃសង្គមដែលអាចរួមរស់នឹងជនបរទេស ដែលត្រូវឆ្ពោះទៅ (ចក្ខុវិស័យ 3)

### សង្គមមានសុវត្ថិភាព គ្មានការបារម្ភ

សង្គមដែលជនបរទេសក៏អាចចូលរួមបង្កើតជាមួយគ្នាបាន ឆ្ពោះទៅអនាគត ហើយអាចរស់នៅដោយមានសុវត្ថិភាព និងគ្មានការបារម្ភទាំងអស់គ្នា

### សង្គមពោរពេញទៅដោយថាមពល និងមានភាពសំបូរបែប

មនុស្សទាំងអស់ រួមទាំងជនបរទេសដែលមានប្រវត្តិផ្សេងៗគ្នា អាចចូលរួមក្នុងសង្គម បញ្ចេញសមត្ថភាពរបស់ខ្លួនជាអតិបរមាបាន ពោរពេញទៅដោយថាមពល និងភាពសំបូរបែប

### សង្គមដែលគោរពសេចក្តីថ្លៃថ្នូររបស់បុគ្គល និងសិទ្ធិមនុស្ស

សង្គមដែលគោរពសេចក្តីថ្លៃថ្នូរនិងសិទ្ធិមនុស្សរបស់មនុស្សគ្រប់រូប រួមទាំងជនបរទេស ហើយអាចរស់នៅដោយគ្មានការរើសអើង

## 2 បញ្ហាប្រឈមរយៈពេលមធ្យមនិងវែងដែលត្រូវដោះស្រាយ (ចំណុចសំខាន់ៗ 4)

1 សកម្មភាពអប់រំភាសាជប៉ុន ជាដើម ដើម្បីឱ្យអាចចូលរួមក្នុងសង្គម និងធ្វើការប្រាស្រ័យទាក់ទងបានរលូន

2 ការបញ្ជូនព័ត៌មាន និងការពង្រឹងប្រព័ន្ធពិគ្រោះចំពោះជនបរទេសជាអាទិ៍

3 ជំនួយទៅតាមដំណាក់កាល និងវដ្តនៃជីវិត

4 សកម្មភាពដើម្បីរៀបចំមូលដ្ឋានគ្រឹះនៃសង្គមមួយដែលអាចរួមរស់ជាមួយគ្នា

# 3 សកម្មភាពសំខាន់ៗពាក់ព័ន្ធនឹងចំណុចសំខាន់ៗ

## 1. សកម្មភាពអប់រំភាសាជប៉ុន ជាដើម ដើម្បីឱ្យអាចចូលរួមក្នុងសង្គម និងធ្វើការប្រាស្រ័យទាក់ទងបានរលូន

○ត្រូវជម្រុញឱ្យបានជាក់លាក់នូវការបង្កើតប្រព័ន្ធជាសកល ដើម្បីពង្រឹងការអប់រំភាសាជប៉ុនដោយរាជធានី និងខេត្ត រួមទាំងការជួយដល់ការអប់រំដែលស្រុកឃុំភូមិបានសហការនឹងរាជធានីខេត្តធ្វើ【ក្រសួងអប់រំនិងវិទ្យាសាស្ត្រ】《1》

○ការអភិវឌ្ឍគំរូនៃការអប់រំ តាមវិស័យនីមួយៗ ទៅតាមខ្លឹមសារ ឬកម្រិតនៃការអប់រំដែលមានបង្ហាញក្នុង "ក្របខណ្ឌយោងស្តីពីការអប់រំភាសាជប៉ុន"【ក្រសួងអប់រំនិងវិទ្យាសាស្ត្រ】《3》

○រៀបចំបរិស្ថានដែលអាចសិក្សានូវចំណេះដឹងស្តីពីប្រព័ន្ធសន្តិសុខសង្គម ជាអាទិ៍ តាមរយៈការបង្កើតនិងប្រើវីដេអូ ណែនាំអំពីជីវភាពរស់នៅ(ផ្តល់ព័ត៌មានមូលដ្ឋានដើម្បីរស់នៅៗជប៉ុន, ការសិក្សាភាសាជប៉ុនបឋម)(រួមទាំងមុនពេលមកជប៉ុន)【ក្រសួងយុត្តិធម៌】《6》

○ការអភិវឌ្ឍ និងផ្តល់នូវឯកសារសិក្សាភាសាជប៉ុនតាមរយៈICT ទៅតាមទិដ្ឋភាពនៃការរស់នៅ【ក្រសួងអប់រំនិងវិទ្យាសាស្ត្រ】《8》

○ការបង្កើតបរិស្ថានសិក្សាភាសាជប៉ុននៅក្រៅប្រទេស ដើម្បីឱ្យមានសមត្ថភាពប្រាស្រ័យទាក់ទងបានរលូនមុនពេលមកជប៉ុន【ក្រសួងការបរទេស】《9》

○ការរៀបចំនូវប្រព័ន្ធស្តីពីលក្ខណ:សម្បត្តិគ្រូភាសាជប៉ុន និងប្រព័ន្ធទទួលស្គាល់ដោយស្ថាប័នអប់រំភាសាជប៉ុន【ក្រសួងអប់រំនិងវិទ្យាសាស្ត្រ】《11》

## 2 ការបញ្ជូនព័ត៌មាន និងការពង្រឹងប្រព័ន្ធពិគ្រោះចំពោះជនបរទេស ជាអាទិ៍

○បង្កើត "សៀវភៅណែនាំអំពីការរស់នៅ និងការងារ" និង "គេហទំព័រសេវាកម្មសាធារណ:ជួយដល់ការរស់នៅរបស់ជនបរទេស" ព្រមទាំងធ្វើការផ្សព្វផ្សាយជាសាធារណ:【ក្រសួងយុត្តិធម៌】《17》

○ទទួលបានព័ត៌មានឆាប់រហ័សតាមរយ:ទម្រង់ Mynaportal ជាដើម និងការពិចារណាលើការផ្សព្វផ្សាយព័ត៌មានតាមទម្រង់ Order made និងទម្រង់Push【ក្រសួងយុត្តិធម៌】<<18>>

○ជម្រុញនូវការបង្កើតកន្លែងពិគ្រោះតាមច្រកតែមួយ តាមរយ:ការផ្តល់ជំនួយដើម្បីរៀបចំបរិស្ថានទទួលជនបរទេស ជាអាទិ៍【ក្រសួងយុត្តិធម៌】《20》

○ចំពោះបច្ចេកទេសបកប្រែពហុភាសា សកម្មភាពសំដៅពង្រីកដល់21ភាសាសំខាន់ៗ ដើម្បីសម្រេចបានកម្រិតប្រើការជាក់ស្តែង "បកប្រែប្រពេញ"【ក្រសួងកិច្ចការផ្ទៃក្នុង និងទូរគមនាគមន៍】<<23>>

○អនុវត្តការពិគ្រោះរួមនឹងស្ថាប័នផ្សេងទៀត ដើម្បីជួយជនបរទេសក្នុងតំបន់ ជាអាទិ៍【ក្រសួងយុត្តិធម៌】《27》

○អនុវត្តការបណ្តុះបណ្តាលសម្រាប់ផ្សព្វផ្សាយភាសាជប៉ុនងាយស្រួល ជាអាទិ៍【ក្រសួងយុត្តិធម៌】【ក្រសួងអប់រំនិងវិទ្យាសាស្ត្រ】《31》《32》

## 3 ជំនួយទៅតាមដំណាក់កាល និងវដ្តនៃជីវិត

○អនុវត្តគម្រោងមូលដ្ឋានគាំទ្រការចិញ្ចឹមកូន ដោយផ្តល់កន្លែងដែលឪពុកម្តាយកំពុងចិញ្ចឹមកូនអាចប្រាស្រ័យទាក់ទងគ្នា ឬអាចពិគ្រោះបាន【ទីភ្នាក់ងារកិច្ចការកុមារ និងគ្រួសារ】<<33>>

○លើកកំពស់ការគ្រប់គ្រងនិងក្តាប់ជាមួយគ្នានូវស្ថានភាពនៃការចូលសាលារបស់កុមារបរទេស តាមរយ:ការប្រើប្រព័ន្ធគោលបញ្ជីមូលដ្ឋាននៃប្រជាជន និងបញ្ជីក្មេងត្រូវចូលសាលា【ក្រសួងអប់រំនិងវិទ្យាសាស្ត្រ】《36》

○ជម្រុញនូវការជ្រើសរើសសិស្សបរទេសចូលវិទ្យាល័យរដ្ឋ ដោយមានកំណត់កូតាពិសេសសម្រាប់ជនបរទេស និងធ្វើការពិរណាពិសេសចំពោះសិស្សទាំងនេះនៅពេលប្រឡង【ក្រសួងអប់រំនិងវិទ្យាសាស្ត្រ】《47》

○ការបង្កើតប្រព័ន្ធអនុវត្តការណែនាំពិសេសអំពីភាសាជប៉ុនក្នុងការកម្មវិធីសិក្សានៅតាមវិទ្យាល័យ【ក្រសួងអប់រំនិងវិទ្យាសាស្ត្រ】《49》

○ប្រឹក្សាពិគ្រោះអំពីការងារសមស្របដោយមានអ្នកពិគ្រោះជំនាញ និងអ្នកបកប្រែនៅតាមកន្លែងសេវាកម្មការងារសម្រាប់ជនបរទេស នៅមជ្ឈមណ្ឌលស្វែងរកការងារ ហេឡូវើក និងផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីការគ្រប់គ្រងការងារសម្រាប់ជនបរទេស[ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព]<<57>>

○អនុវត្តការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព និងការពិនិត្យឡើងវិញជាចាំបាច់ក្នុងវិធានការនានាទាក់ទងនឹងការលើកកម្ពស់ការចូលធ្វើការរបស់និស្សិតអន្តរជាតិនៅក្នុងក្រុមហ៊ុនក្នុងស្រុក។ល។ ព្រមទាំងអនុវត្តកិច្ចការដើម្បីបង្កើនអត្រាការងារក្នុងស្រុកបន្ថែមទៀត[ក្រសួងអប់រំវប្បធម៌ និងវិទ្យាសាស្ត្រ]<<59>>

○ការអនុវត្តការបណ្តុះបណ្តាលវិជ្ជាជីវ:ដោយពិចារណាដល់សមត្ថភាពភាសាជប៉ុន ចំពោះជន បរទេសដែលស្នាក់នៅអចិន្ត្រៃយ៍【ក្រសួងសុខាភិបាល សុខុមាលភាពនិងការងារ】《61》

○ការបន្តនិងពង្រឹងការផ្សព្វផ្សាយ និងបញ្ជ្រាបអំពីរបបសោធននិវត្តន៍【ក្រសួងសុខាភិបាល សុខុមាលភាពនិងការងារ】《63》

○ការក្តាប់នូវស្ថានភាពពិតតាមរយ: "ការអង្កេតមូលដ្ឋានចំពោះជនបរទេសស្នាក់នៅជប៉ុន" ជាអាទិ៍【ក្រសួងយុត្តិធម៌】《66》

## 4 សកម្មភាពដើម្បីរៀបចំមូលដ្ឋានគ្រឹះនៃសង្គមមួយដែលអាចរួមរស់ជាមួយគ្នា

○"ការបង្កើតខែសិក្សាអំពីចំណេះដឹងស្តីពីការរួមរស់ជាមួយជនបរទេស(ឈ្មោះបណ្តោះអាសន្ន)" និងការអនុវត្តនូវកម្មវិធីសិក្សាអំពីចំណេះដឹងផ្សេងៗ【ក្រសួងយុត្តិធម៌】《67》《68》

○ការផ្សព្វផ្សាយនិងការជម្រុញឱ្យបានកាន់តែពេញលេញនូវការអប់រំដោយផ្អែកលើគំនិតយល់ដឹងអំពីវប្បធម៌បរទេស និងការរួមរស់ក្រោមវប្បធម៌សំបូរបែបតាមសាលា【ក្រសួងអប់រំនិងវិទ្យាសាស្ត្រ】《71》

○ប្រើស្ថិតិស្តីពីជនបរទេសដែលស្នាក់នៅជាអាទិ៍ បង្កើតតារាងស្ថិតិថ្មីដែលអាចក្តាប់បាននូវស្ថានភាពនៃជីវភាពរស់នៅរបស់ជនបរទេស ដោយបែងចែកតាមសញ្ជាតិ លក្ខណ:សម្បត្តិនៃការស្នាក់នៅ និងប្រភេទការងារ ជាអាទិ៍ ព្រមទាំងប្រកាសផ្សាយជាសាធារណ:នូវព័ត៌មានទាំងនេះ។【ក្រសួងយុត្តិធម៌】《74》

○ធ្វើការស្រាវជ្រាវស្ថិតិ ដើម្បីគ្រប់គ្រងការជួលកម្មករ ដូចជាលក្ខខណ្ឌការងាររបស់ពលករបរទេស, និងក្តាប់នូវស្ថានភាពនៃការចល័តការងារ[ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព]<<75>>

○អនុវត្តគម្រោងសាកល្បង ដើម្បីជួយដល់អង្គការឯកជនដែលធ្វើសកម្មភាពជំនួយចំពោះជនបរទេសដែលត្រូវការជំនួយ【ក្រសួងយុត្តិធម៌】《80》

○ការពិចារណាអំពីការបង្កើតប្រព័ន្ធដែលអាចក្តាប់បានជារួម នូវព័ត៌មានចាំបាច់សម្រាប់ការគ្រប់គ្រងការស្នាក់នៅ ដោយទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍【ក្រសួងយុត្តិធម៌】《82》

○ធ្វើឱ្យមានភាពងាយស្រួលក្នុងការប្រើ តាមរយ:ការរួមបញ្ចូលប័ណ្ណអត្តសញ្ញាណ និងបណ្ណស្នាក់នៅ【ក្រសួងយុត្តិធម៌】《85》

○ពិចារណាអំពីការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ជួយជនបរទេស ឬបង្កើតរបបវិញ្ញាបនប័ត្រស្តីពីធនធានមនុស្សសម្រាប់ជួយដែលមានជំនាញខ្ពស់ជាអាទិ៍【ក្រសួងយុត្តិធម៌】《86》

※លេខវិធានការពណ៌ក្រហមគឺជាវិធានការថ្មីតាមការផ្លាស់ប្តូរផ្នែកខ្លះក្នុងឆ្នាំ2023

## 4 ប្រព័ន្ធជម្រុញ

- ◆ កម្លុងពេលនៃផែនការ គឺរហូតដល់ឆ្នាំ 2026
- ◆ ត្រូវសួរមតិយោបល់អ្នកបញ្ញវ័ន ហើយធ្វើការបញ្ជាក់អំពីវឌ្ឍនភាពរាល់ឆ្នាំ ព្រមទាំងពិនិត្យឡើងវិញនូវវិធានការតាមការចាំបាច់
- ◆ ក្នុងចំណោមវិធានការសរុបទូទៅ ត្រូវបង្ហាញច្បាស់លាស់អំពីវិធានការដែលត្រូវអនុវត្តក្នុងឆ្នាំសារពើពន្ធនេះ

## 5 ចំណុចកែសម្រួលប្រចាំឆ្នាំ2023។ល។

### ប្រការចង្អុលបង្ហាញសំខាន់ៗពីអ្នកជំនាញ

- ➢ តារាងបន្ទាត់ក្លាយជាខ្សែបន្ទាត់តែមួយ ហើយមិនដឹងថាវាជាការពិតបែបណា ចំពោះវិធានការអនុវត្តរាល់ឆ្នាំ។
- ➢ បើគេប្រែក្លាយ(សូចនាករ KPI)ជាសូចនាករOutput ឬសូចនាករOutcome នោះវានឹងធ្វើឱ្យប្រសិទ្ធភាពគោលនយោបាយកាន់តែងាយស្រួលយល់។
- ➢ ដោយសារវាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងអំពីការផ្លាស់ប្តូរតាមឆ្នាំ ចំពោះតួលេខនៃសូចនាករ KPI យើងចង់ឱ្យបង្ហាញការប្រៀបធៀបជាមួយនឹងតួលេខ មុនពេលផែនទីបង្ហាញផ្លូវត្រូវបានសម្រេច។
- ➢ យើងយល់ថាពិបាកក្នុងការកំណត់សូចនាករKPIសម្រាប់វិធានការអនុវត្តថ្មី ប៉ុន្តែប្រសិនបើលើកពីសូចនាករKPIទៅហើយ ចាំបាច់ធ្វើឱ្យច្បាស់លាស់។
- ➢ ប្រការចង្អុលបង្ហាញចំពោះវិធានការដោយឡែក ផ្សេងទៀត

### ការកែសម្រួលសំខាន់ៗ

- កែសម្រួលតារាងដំណើរការ 70ករណី
- កែសម្រួលសូចនាករKPI 28ករណី
- កែសម្រួលខ្លឹមសារឬវិធានការថ្មី 13ករណី